# ដ្យាក្រាមទី៤៖ រោងចក្រ សិប្បកម្មកែច្នៃជ័រនិងឈើកៅស៊ូ ឆ្នាំ២០១៧ -២០២១




ក្នុងឆ្នាំ២០២១នេះ រោងចក្រ សិប្បកម្មកែច្នៃកៅស៊ូ និងឈើកៅស៊ូចំនួន៦០កន្លែងបានផ្អាកដំណើរការ ក្នុងនោះរោងចក្រកែច្នៃកៅស៊ូធម្មជាតិបញ្ជាក់តាមលក្ខណៈបច្ចេកទេស (TSR: Technically Specified Rubber) ចំនួន១៥កន្លែង រោងចក្រកែច្នៃទឹកជ័រខាប់ (CL: Concentrated Latex) ចំនួន១កន្លែង សិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយមានផ្សែង (RSS: Ribbed Smoked Sheet) និងសិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ក្តៅ (ADS: Air-Dried Sheet) មានចំនួន៣៩កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូ (RWF: Rubber Wood Factory) ចំនួន៥កន្លែង។ ការផ្អាកដំណើរការនេះ ដោយសារខ្វះវត្ថុធាតុដើមដែលជាកៅស៊ូមិនទាន់កែច្នៃមួយចំនួនត្រូវបាននាំចេញក្រៅផ្លូវការ។